**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ ភទ្របទ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩*
*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីជំនួបសម្តែងការគួរសមរវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ
# លោក បាហ្គាវ ដាសគុបតា (Bhargav Dasgupta) អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

នាព្រឹកថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០២៥, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន អនុញ្ញាតទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក **បាហ្គាវ ដាសគុបតា** (Bhargav Dasgupta) អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលបន្ទុកផ្នែកដំណោះស្រាយទីផ្សារ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃធនាគារអភិវឌ្ឍន៍អាស៊ី នៅកម្ពុជា ចាប់ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២៥ ។

ជាមួយនឹងកិច្ចស្វាគមន៍, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះការចូលរួមដ៏សំខាន់របស់ ADB ក្នុងការចាប់ផ្តើមប្រតិបត្តិការមុនគេក្នុងចំណោមបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាក្នុងតំបន់ និងសកលលោក សម្រាប់ការគាំទ្រដំណើការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។ កិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និង ADB រយៈពេលជាង ៣០ឆ្នាំ មកនេះ បានវិវឌ្ឍឈានឡើងជាបន្តបន្ទាប់រហូតបង្កើតបានក្របខ័ណ្ឌ "**យុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជា**" ដ៏មានសារសំខាន់ដែលផ្តល់ការគាំទ្រយ៉ាងរឹងមាំដល់ការអភិវឌ្ឍវិស័យអាទិភាពសំខាន់ៗជាច្រើនរបស់កម្ពុជា សំដៅជំរុញកំណើនប្រកបដោយភាពធន់ ចីរភាព និងបរិយាប័ន្ន ។ ក្នុងចំណោមវិស័យអាទិភាពដែល ADB បាននិងកំពុងផ្តល់ការគាំទ្រដល់ការពង្រឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ, វិស័យសហគ្រាសធុនតូច និងមធ្យម (SMEs), វិស័យហិរញ្ញវត្ថុ, ហិរញ្ញប្បទានពាណិជ្ជកម្ម, កសិធុរកិច្ច និងការអភិវឌ្ឍភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPP) ជាដើម ។ បន្ថែមលើនេះ, "**ការគាំទ្រវិស័យឯកជន**" ត្រូវបានតម្កល់ជាចលករដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចសង្គម ស្របតាម "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី១**" របស់រាជរដ្ឋាភិបាល ។ តាមរយៈភាពជាដៃគូដ៏ល្អនេះ, ADB នឹងបន្តផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់កម្ពុជា រួមគ្នាដោះស្រាយបញ្ហាប្រឈមនានា ដើម្បីកម្ពុជាអាចសម្រេចបានជោគជ័យនូវការចាកចេញពីចំណាត់ថ្នាក់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនៅពេលខាងមុខ ។

លោក **បាហ្គាវ ដាសគុប្តា** បានថ្លែងអំណរគុណចំពោះការស្វាគមន៍ដ៏កក់ក្តៅរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និងបានគូសរំលេចថា វិស័យអាទិភាពរបស់រាជរដ្ឋាភិបាលមានសង្គតិភាពទៅនឹងគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ ADB គឺការអភិវឌ្ឍវិស័យឯកជន និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ។ លោកបានបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ ADB ក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាលើការអភិវឌ្ឍវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា សំដៅឈានឆ្ពោះទៅសម្រេចនូវចក្ខុវិស័យឆ្នាំ ២០៥០ របស់កម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់ ។ ជាក់ស្តែង, ADB បានផ្តល់ការគាំទ្រវិស័យឯកជនកម្ពុជាដោយផ្ទាល់ទាំងជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងការផ្តល់ហិរញ្ញប្បទានសម្រាប់ SMEs កម្ពុជាដោយផ្ទាល់ ក្រោមកញ្ចប់កម្មវិធី ADB Frontier ដែលជាកម្មវិធីផ្តល់ហិរញ្ញប្បទានជាដើមទុនដំបូងសម្រាប់គាំទ្រ SMEs ហើយកម្ពុជាជាប្រទេសដែល ADB ជ្រើសរើសក្នុងការផ្តល់ទុនសាកល្បងដំបូងគេក្នុងចំណោមប្រទេសក្នុងតំបន់ ។ ការជំរុញប្រសិទ្ធភាពពាណិជ្ជកម្ម និងការប្រកួតប្រជែងនៅកម្ពុជា ដោយផ្តោតលើកំណែទម្រង់ ០៣ គឺ៖ (១)ការបង្កើនបរិយាកាសអំណោយផលសម្រាប់វិនិយោគទុន និងអាជីវកម្ម, (២)ការលើកកម្ពស់ពាណិជ្ជកម្មមីក្រូ, ខ្នាតតូច, និងខ្នាតមធ្យម និង (៣)ការកែលម្អគោលនយោបាយពាណិជ្ជកម្ម និងការបង្កើនប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម ។ ការផ្តល់ហិរញ្ញប្បទានសម្រាប់ការគាំទ្រដល់ការវិនិយោគរបស់វិស័យឯកជន តាមរយៈការផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាប និងក្នុងលក្ខខណ្ឌអំណោយផលសម្រាប់សកម្មភាពការងារផ្សេងៗរបស់ SMEs សំដៅចូលរួមចំណែកដល់ការគ្រប់គ្រងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ការជំរុញការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍភាពជាដៃគូរវាងរដ្ឋ និងឯកជន ផងដែរ ។

ជាមួយគ្នានេះ, ជាមួយការថ្លែងអំណរគុណចំពោះ ADB សម្រាប់ការគាំទ្ររបៀបវារៈនៃការអភិវឌ្ឍជារួមរបស់រាជរដ្ឋាភិបាល និងបានវាយតម្លៃខ្ពស់លើការចូលរួមរបស់ ADB ក្នុងការគាំទ្រវិស័យឯកជនក្នុងនោះ ការរៀបចំយន្តការ PPP និងការផ្តល់ជំនួយបច្ចេកទេសសម្រាប់ការរៀបចំច្បាប់ PPP, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្នើឲ្យ ADB បន្តផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការពង្រឹងយន្តការ PPP ឱ្យកាន់តែមានភាពទាក់ទាញថែមទៀត ។ ជាក់ស្តែង, **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ** បានស្នើ ADB បន្តគាំទ្រការពង្រឹងវិស័យឯកជនកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់វិស័យឯកជន (Non-Sovereign Loan) និង គិតគូរបន្ថែមលើ៖ (១) គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការពង្រឹងនគរូបនីយកម្ម, (២) ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាវិស័យគន្លឹះលើការជំរុញការអភិវឌ្ឍវិស័យឯកជន, ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គមជារួម, (៣) កំណែទម្រង់គោលនយោបាយគាំទ្រការអភិវឌ្ឍ និងបង្កើនបរិយាកាសអំណោយផលដល់វិស័យឯកជន និងពាណិជ្ជកម្ម, និង (៤)ការគាំទ្រផ្នែកជំនាញ, បច្ចេកវិទ្យា និងការកៀរគរធនធានបន្ថែម សម្រាប់ជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង SMEs កម្ពុជា ដើម្បីអាចរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និង បានជូនពរលោក **បាហ្គាវ ដាសគុប្តា** និងសហការីទទួលបាន នូវលទ្ធផលផ្លែផ្កាក្នុងដំណើរទស្សនកិច្ចនៅកម្ពុជា ។